**CCHR / CCIM / CICA / CDP / CFSWF / CHRAC / LICADHO / CWCD / CYN / CCFC / COMFREL / CLEC / CPN / CCC / CARAM / HRTF / IDEA / KYA / LAC / PAC / STT**

# ការចោទប្រកាន់ប្រឆាំងទៅលើបុគ្គលិកសមាគមន៍អាដហុក បង្ហាញឲ្យឃើញពីការគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរបំផុតក្នុងរយៈពេលមួយទសវត្សរ៍នេះ ទៅលើការងារសិទ្ធិមនុស្សនៅកម្ពុជា

**ភ្នំពេញ (ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២)៖** យើងខ្ញុំទាំងអស់គ្នា ជាក្រុមសង្គមស៊ីវិលដែលមានរាយនាមដូចខាងក្រោម មានការសោកស្តាយយ៉ាងខ្លាំងទៅលើសេចក្តីសម្រេចរបស់តុលាការរាជធានីភ្នំពេញក្នុងការបន្តធ្វើការចោទប្រកាន់បែបនយោបាយ ប្រឆាំងនឹងអ្នកធ្វើការផ្នែកសិទ្ធិមនុស្សដែលនិយាយឥតសំចៃ លោក ចាន់ សុវ៉េត ទៅលើសកម្មភាពស្របច្បាប់ដែលទាក់ទងនឹងការងាររបស់គាត់។

លោក សុវ៉េត ត្រូវបានកោះហៅឲ្យចូលធ្វើការបកស្រាយលើការចោទប្រកាន់ពីការជួយដោយខុសច្បាប់ដល់អ្នកភូមិខេត្តក្រចេះ ដែលត្រូវបានវាយលុកដោយកងកម្លាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលកាលពីខែឧសភា។ កុមារីអាយុ ១៤ឆ្នាំម្នាក់ ត្រូវបានសំលាប់នៅក្នុងប្រតិបត្តិការនោះ។ អាជ្ញាធរ អះអាងថាអ្នកភូមិបានរៀបចំផែនការធ្វើអបគមន៍ចេញពីប្រទេសកម្ពុជា និងបង្កើតរដ្ឋផ្ទាល់ខ្លួន។

អាជ្ញាធរអះអាងថា លោក សុវ៉េត ដែលជាបុគ្គលិកដ៏លេចធ្លោនៃសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) តាំងពីឆ្នាំ១៩៩៥ បានផ្តល់ជំនួយមិនជាក់លាក់ដល់បុគ្គលម្នាក់ក្នុងចំណោមបុគ្គលដែលសង្ស័យថាជាមេដឹកនាំទាំងអស់នៃ "ចលនាអបគមន៍"។ លោក សុវ៉េត គឺជាបុគ្គលដែលនិយាយឥតសំចៃរិះគន់ម្នាក់ជាយូរមកហើយ ក្នុងចំណោមបុគ្គលជាច្រើនទៅលើកំណត់ត្រាតាមដានសិទ្ធិមនុស្សរបស់រាជរដ្ឋាភិបាលកម្ពុជា។

ការកោះហៅ ត្រូវបានចេញក្នុងរយៈពេលតិចជាង ២សប្តាហ៍ បន្ទាប់ពីការផ្សាយទូទាំងប្រទេស នូវសុន្ទរកថារបស់សម្តេចនាយករដ្ឋមន្ត្រី ដែលសម្តេចបានសុំឲ្យបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលម្នាក់ដោយមិនបញ្ចេញឈ្មោះ ឲ្យចេញមក "សារភាព" នូវទង្វើរបស់ខ្លួនក្នុងការផ្តល់ជំនួយដល់អ្នកភូមិខេត្តក្រចេះ។ ក្នុងអំឡុងពេលសុន្ទរកថារបស់សម្តេចនាយករដ្ឋមន្ត្រី លោកបានបែរទៅរកសមាជិករដ្ឋាភិបាលរបស់លោក ហើយមានប្រសាសន៍សួរថា៖ "ដូចហៅសួរឬនៅ? អត់ទាន់ហៅសួ? អត់ទាន់ហៅសួ"។ ឯកសារកត់ត្រាបង្ហាញថា សំណុំរឿងព្រហ្មទណ្ឌប្រឆាំងនឹងលោក សុវ៉េត ត្រូវបានបើកត្រឹមតែរយៈពេល ៤៨ ម៉ោងប៉ុណ្ណោះ បន្ទាប់ពីសុន្ទរកថារបស់លោកនាយករដ្ឋមន្ត្រី។

លោក សួន ប៊ុនស័ក្តិ លេខាប្រតិបត្តិនៃ CHARC បានមានប្រសាសន៍ថា៖ "ការកោះហៅលោក សុរ៉េត បង្ហាញឲ្យឃើញពីការតបទល់យ៉ាងខ្លាំងមកលើកិច្ចការសិទ្ធិមនុស្សដែលយើងខ្ញុំបានជួបរយៈពេលមួយទសវត្សន៍នេះ។ លោក បានបន្តទៀតថា៖ "នេះគឺជាការព្យាយាមចោទជាបទល្មើសព្រហ្មទណ្ឌមកលើសកម្មភាពស្របច្បាប់របស់អង្គការក្រៅរដ្ឋាភិបាល។"

ដោយយោងតាមដីកាកោះហៅដែលបានចេញដោយចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ លោក ឆៃ វីរៈ លោកសុរ៉េត ត្រូវបានសង្ស័យថា បានល្មើសនឹងមាត្រា ៥៤៩ នៃក្រមព្រហ្មទណ្ឌ ដែលហាមប្រាមក្នុងការផ្តល់ជំនួយដល់ចារីនៃបទឧក្រិដ្ឋ។ បទល្មើសនេះ តម្រូវឲ្យព្រះរាជអាជ្ញាបញ្ជាក់នូវការពិតថា អ្នកទទួលជំនួយបានប្រព្រឹត្តបទឧក្រិដ្ឋ។ ក៏ប៉ុន្តែមិនមានភស្តុតាងគួរឲ្យជឿណាមួយនោះទេថា ពិតជាមានបទល្មើសព្រហ្មទណ្ឌពិតប្រាកដ។

អាជ្ញាធរ មិនបានលើកឡើងនូវភស្តុតាងនៃចលនាអបគមន៍អ្វី ជាជាងការអះអាងផ្ទាល់មាត់នោះទេ។ ប៉ុន្តែ នេះត្រូវបានដឹងច្បាស់ណាស់ថា ក្រុមអ្នកភូមិ ត្រូវបានបង្កឲ្យមានភាពច្របូកច្របល់នៅក្នុងជម្លោះដីធ្លីដ៏ជំរ៉ាំរ៉ៃជាមួយក្រុមហ៊ុន Casotim ដែលជាក្រុមហ៊ុនកាន់កាប់ដីសម្បទាន ១៥.០០០ ហិកតា នៅក្បែរភូមិរបស់អ្នកភូមិទាំងនោះ។

ទាំងច្បាប់ជាតិ និង ច្បាប់អន្តរជាតិក៏បានចែងថា មិនមានបទល្មើសព្រហ្មទណ្ឌនោះទេប្រសិនបើមិនមានចេតនាប្រព្រឹត្តបទល្មើស។ ដោយអវត្តមាននៃភស្តុតាងដែលគួរឲ្យជឿនៃបទឧក្រិដ្ឋនេះ ការផ្តល់ជំនួយរបស់លោកសុរ៉េត ដល់ជនរងគ្រោះនៃការរំលោភដីធ្លី (ដែលធ្លាក់យ៉ាងច្បាស់លើអណត្តិរបស់សមាគមន៍ អាដហុក) មិនអាច និងមិនត្រូវអាចចោទប្រកាន់បទល្មើសព្រហ្មទណ្ឌនោះទេ។

ការកោះហៅលោក សុរ៉េត កើតឡើងបន្ទាប់ពីការចាប់ខ្លួនម្ចាស់ស្ថានីយ៍វិទ្យុឯករាជ្យគឺលោក ម៉ម សូណង់ដូ ដែលក៏ត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌទាក់ទងនឹង "ចលនាអបគមន៍" នៅខេត្តក្រចេះផងដែរ។ បច្ចុប្បន្ន លោកត្រូវបានឃុំខ្លួនក្នុងពន្ធនាគារ ដោយរងចាំបើកសវនាការ។ លោក អាចប្រឈមមុខនឹងការជាប់ពន្ធនាគាររយៈពេល ៣០ឆ្នាំ ប្រសិនបើការចោទប្រកាន់ទាំងអស់បានសម្រេច។ ដូចនឹងករណីលោក សុរ៉េត លោកនាយករដ្ឋមន្ត្រី ក៏បានអំពាវនាវឲ្យមានការចាប់ខ្លួនលោក សូណង់ដូនៅក្នុងពេលថ្លែងសុន្ទរកថាដែលបានផ្សាយទូទាំងប្រទេស។

នាយិកាអង្គការសិទ្ធិមនុស្ស លីកាដូ អ្នកស្រី ណាលី ពីឡូក បានមានប្រសាសន៍ថា៖ "នេះគឺជាឆ្នាំដ៏អាក្រក់បំផុតសម្រាប់ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា នៅក្នុងរយៈពេលមួយទស្សវត្សន៍នេះដោយការប្រើគ្រប់មធ្យោបាយ"។ អ្នកស្រីបានបន្ថែមទៀតថា៖ "យើងបានឃើញនូវការកើនឡើងនៃ

**CCHR / CCIM / CICA / CDP / CFSWF / CHRAC / LICADHO / CWCD / CYN / CCFC / COMFREL / CLEC / CPN / CCC / CARAM / HRTF / IDEA / KYA / LAC / PAC / STT**

ការប្រើហិង្សា ការកើនឡើងនៃការប្រើប្រាស់កងកម្លាំងប្រដាប់អាវុធរបស់អាជ្ញាធរ ការកើនឡើងនៃការសម្លាប់ ការកើនឡើងនៃការគម្រាមកំហែង តាមប្រព័ន្ធតុលាការ ហើយឥឡូវនេះយើងបានឃើញពីការព្យាយាមចោទប្រកាន់បទល្មើសព្រហ្មទណ្ឌមកលើការងារសិទ្ធិមនុស្សដែលស្របច្បាប់" ។

"ករណីនេះ បានគម្រាមកំហែង នឹងបំផ្លាញគ្រប់សសៃទាំងអស់ របស់ក្រុមបណ្តាញសង្គមស៊ីវិលរបស់កម្ពុជា (ដែលជាទិដ្ឋភាពវិជ្ជមានមួយចុងក្រោយនៃកេរ្តិ៍តំណែលរបស់អង្គការសហប្រជាជាតិ UNTAC)"។

លោក សុវ៉េត ត្រូវបានកោះហៅឲ្យចូលខ្លួនដើម្បីធ្វើការសាកសួរនៅសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី ២៤ ខែសីហា នៅម៉ោង ៨ ព្រឹក។ ប្រសិនបើត្រូវធ្វើការផ្តន្ទាទោស លោកនឹងប្រឈមមុខនឹងការជាប់ពន្ធនាគារពី មួយឆ្នាំ ទៅបីឆ្នាំ ហើយពិន័យជាប្រាក់ពី ៥០០ ដុល្លាអាមេរិក ទៅ ១៥០០ ដុល្លាអាមេរិក។

យើងខ្ញុំ ដែលមានរាយនាមដូចខាងក្រោម សូមធ្វើការស្នើសុំដោយទទូចដល់សាលាដំបូងរាជធានីភ្នំពេញ សុំលោកមេត្តារក្សានូវឯករាជ្យភាពរបស់លោកនៅក្នុងករណីនេះ។ យើងខ្ញុំ ក៏ស្នើសុំអំពាវនាវដល់ស្ថាប័ននីតិប្រតិបត្តិ សុំកុំធ្វើអន្តរាគមន៍ទៅលើនីតិវិធីរបស់តុលាការ។ យើងខ្ញុំក៏ជឿជាក់ថា ការអនុវត្តនូវគោលការណ៍ឯករាជ្យ នឹងលាងសំអាត លោក សុវ៉េតពីការចោទប្រកាន់ខាងលើនេះ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា*(CCHR)*
មជ្ឈមណ្ឌលកម្ពុជាសម្រាប់ប្រព័ន្ធផ្សព្វផ្សាយពត៌មានឯករាជ្យ*(CCIM)*
សមាគមមន្ត្រីរាជការកម្ពុជា*(CICA)*
ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា *(CDP)*
សហព័ន្ធសហជីពកម្មករចំនីអាហារ និងសេវាកម្មកម្ពុជា*(CFSWF)*
គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា *(CHRAC)*
សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ*(LICADHO)*
មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្មករកម្ពុជា*(CWCD)*
បណ្តាញយុវជនកម្ពុជា*(CYN)*
សម្ព័ន្ធសហគមន៍កសិករកម្ពុជា*(CCFC)*
គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា *(COMFREL)*

**CCHR / CCIM / CICA / CDP / CFSWF / CHRAC / LICADHO / CWCD / CYN / CCFC / COMFREL / CLEC / CPN / CCC / CARAM / HRTF / IDEA / KYA / LAC / PAC / STT**

មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍*(CLEC)*

បណ្ដាញកសាងសន្តិភាពសហគមន៍*(CPN)*

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា *(CCC)*

អង្គការខារ៉ាមកម្ពុជា *(CARAM)*

ក្រុមការងារពិសេសសិទ្ធិលំនៅឋាន*(HRTF)*

សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ*(IDEA)*

សមាគមន៍យុវជនកម្ពុជា *(KYA)*

ជំនួយផ្នែកច្បាប់នៃកម្ពុជា *(LAC)*

ចលនាប្រជាពលរដ្ឋសម្រាប់ការផ្លាស់ប្ដូរ*(PAC)*

សមាគមធាងត្នោត*(STT)*